ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២៧២/១៣ - ស្តារខ្សែថ្មី

កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

### ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ស្តារខ្សែថ្មី អ៊ីតែរ៉ឺល មេនូហ្វេកធឺរីង ខូអិលធីឌី**

អាសយដ្ឋាន ៖ ផ្ទះលេខ ១៨ ផ្លូវលេខ បេតុងថ្មី ភូមិសេដា ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១២ ៨០១ ២៨៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ម៉េង សុជាតិ | ប្រធានរដ្ឋបាល |
| ២- លោកស្រី ឡុង លីហ៊ាង | Compliance Officer |
| ៣- លោក ជាតិ ខេមរា | មន្ត្រីជាន់ខ្ពស់ GMAC |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ**

អាសយដ្ឋាន ៖ ការិយាល័យលេខ ៣៥៨ ផ្លូវលំ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥៣ ៥៩ ៥៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការ ៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- នៅពេលក្រុមហ៊ុនគ្មានការងារធ្វើ ហើយកម្មករឈប់សម្រាក សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗទៀត នៅពេញ ១០០ ភាគរយ ជូនកម្មករ និងសងរំលឹកឡើងវិញ ដែលក្រុមហ៊ុនបានផ្តល់ប្រាក់ឈ្នួលជូនកម្មករមិនត្រឹមត្រូវនៅពេលកន្លងមក។

២- សូមឱ្យក្រុមហ៊ុនចាត់វិធានការ តាមច្បាប់ស្តីពីការងារជាបន្ទាន់ ចំពោះប្រធានដេរផ្នែកចិន និងផ្នែកពិនិត្យ ដែលបានបង្ខិតបង្ខំឱ្យកម្មករចូលធ្វើការមុនម៉ោង ៣០ នាទី នៅពេលចេញសម្រាកហូបអាហារថ្ងៃត្រង់ ដោយក្នុងមួយក្រុមៗ កម្មករចូលធ្វើការស្មើ ៥០ ភាគរយ។

៣- សូមឱ្យក្រុមហ៊ុនចាត់វិធានការតាមច្បាប់ស្តីពីការងារជាបន្ទាន់ ចំពោះអ្នកគ្រប់គ្រងទូទៅឈ្មោះ ខេមឌីហៅ អាជេស្តរគ្រាប់ ដែលមានចរិតក្រអឺតក្រទឹម ប្រើពាក្យសម្តី និងកាយវិការមិនសមរម្យមកលើកម្មករ និងធ្វើការគាបសង្កត់ការងារមកលើប្រធានក្រុមខ្មែរ និងកម្មករ ដោយមិនស្តាប់ហេតុផលនៃផលលំបាកផ្សេងៗពីកម្មករ។

៤- សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ៥ ដុល្លារ បន្ថែមទៀត ជូនកម្មករសរុប ១៥ ដុល្លារ ក្នុងមួយខែ។

៥- សូមឱ្យក្រុមហ៊ុនផ្តល់សោហ៊ុយធ្វើដំណើរ ចំនួន ៥ ដុល្លារ បន្ថែម ជូនកម្មករសរុបចំនួន ១៥ ដុល្លារ ក្នុងមួយខែ។

៦- សូមឱ្យក្រុមហ៊ុនផ្តល់ម្សៅទឹកដោះគោ ជូនស្ត្រីដែលមកពីសម្រាលកូនចំនួន ៣ កំប៉ុង ឬប្តូរជាប្រាក់ក្នុងមួយខែ ២០ ដុល្លារ។

៧- សូមឱ្យក្រុមហ៊ុនអនុវត្តការងារបន្ថែមម៉ោងតាមគោលការណ៍ស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំ គំរាមកំហែង ឬចាត់វិធានការណ៍ផ្សេងៗមកលើកម្មករ។

៨- សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួល ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗជូនកម្មការិនី ដែលបានដាក់ច្បាប់សម្រាកមាតុភាពសរុបចំនួនបីខែ មុនថ្ងៃគាត់សម្រាក។

៩- ស្នើសុំឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ទៀងទាត់(លុយព្រីម) តាមសមាមាត្រចំនួនថ្ងៃ ដែលបានដាក់ច្បាប់ឈប់សម្រាក ឬមានធុរះផ្សេងៗ (កម្មករដែលបានដាក់ច្បាប់ឈប់សម្រាកដោយគ្មានជំងឺ និងគ្មានច្បាប់ដំណាច់ឆ្នាំ) ចំពោះកម្មករពេញសិទ្ធិ។

១០- សូមឱ្យក្រុមហ៊ុនអនុវត្តឱ្យបានត្រឹមត្រូវចំពោះបទបញ្ជាផ្ទៃក្នុង លើការឈប់សម្រាករបស់កម្មករ។ករណីកម្មករឈប់សម្រាកដោយឥតច្បាប់ជាប់ៗគ្នាលើសពី ១៦ ថ្ងៃ ទើបចាត់ទុកថា បោះបង់ការងារចោល។

១១- សូមឱ្យក្រុមហ៊ុនរៀបចំបន្ទប់ពេទ្យ និងបន្ថែមចំនួនគ្រែក្នុងបន្ទប់ពេទ្យ។

១២- ស្នើសុំឱ្យក្រុមហ៊ុនតម្លើងថ្លៃបាយថែមម៉ោង ១៦ ទៅ ១៨ ល្ងាច ចំនួន ៣០០០ រៀល។

THE ARBITRATION COUNCIL

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០២៦/១៣ កប/កណ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣។

### សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ លេខ ១០៨ ស.ស.ស.ក.ខ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការស្នើសុំឱ្យជួយដោះស្រាយ សម្របសម្រួល នូវវិវាទការងាររួមចំនួន ១២ ចំណុច ដែលក្រុមហ៊ុន ស្តារឡៃថ៍ មិនព្រមដោះស្រាយ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួមទាំង ១២ ចំណុច ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ០០ ចំណុច និងមិនសះជានឹងគ្នាចំនួន ១២ ចំណុច ។ ចំណុចមិនសះជាដែលនៅសល់ទាំង ១២ ចំណុចត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ស្តារឡៃថ៍ លេខ ០២៦/១៣ ក.ប/កណ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សា លើករណីមិនសះជាទាំង ១២ ចំណុច នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ វេលាម៉ោង ០៨ និង៣០ នាទី ព្រឹក។ ភាគីកម្មករនិយោជិតមិនបានចូលរួមសវនាការអាជ្ញាកណ្តាល តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ នៅថ្ងៃសវនាការ ភាគីតំណាងកម្មករនិយោជិត ដែលមានឈ្មោះ សួស សុខា ជាអគ្គលេខាធិការរងនៃសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ បានបញ្ជាក់តាមទូរស័ព្ទមកលេខាធិការដ្ឋាន

ក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីកម្មករនិយោជិតមិនអាចមកចូលរួមសវនាការអាជ្ញាកណ្តាលបានទេ ដោយមូលហេតុថា កម្មករនិយោជិតឈប់សម្រាកនៅផ្ទះ ដោយសារបញ្ហាកូដកម្ម និងបាតុកម្មសុំដំឡើងប្រាក់ឈ្នួលអប្បបរមាដែលកើតឡើងរាល់ថ្ងៃ ក្នុងពេលបច្ចុប្បន្ន ហើយក៏មិនមានមន្ត្រីណាម្នាក់នៃសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ អាចមកចូលរួមសវនាការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះបានដែរ។ បន្ថែមលើនេះ លោក សួស សុខា បានស្នើសុំក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យបន្តនីតិវិធីតាមផ្លូវច្បាប់របស់ខ្លួនចុះ។ ចំណែកភាគីនិយោជកវិញ បានមកចូលរួមសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស្តារឡៃថ៍ លេខ ០២៦/១៣ កប/កណ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ស្តារឡៃថ៍ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតលេខ ១៣៥៧ កប/អក/វក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល អញ្ជើញនាយកក្រុមហ៊ុន ស្តារឡៃថ៍ ដើម្បីមកជ្រើសរើសអាជ្ញាកណ្តាល។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៣៦៦ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៣៦៧ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣។

**អង្គហេតុ**

- ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារនៅក្នុងសំណុំរឿងនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិតបានអវត្តមាននៅថ្ងៃសវនាការ ដោយគ្មានបញ្ជាក់មូលហេតុត្រឹមត្រូវ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងត្រូវចាត់នីតិវិធីបែបណា ក្នុងករណីអវត្តមានភាគីកម្មករនិយោជិត នៅថ្ងៃសវនាការ?

THE ARBITRATION COUNCIL

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ក្រុមអាជ្ញាកណ្តាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត"*។

ប្រការ ២០ នៃប្រកាសដដែលនេះ ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ។"*

ប្រការ ២១ នៃប្រកាសដដែល ចែងថា៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់"* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា៖ *"ប្រសិនបើភាគីណាមួយ មិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន "* ។

យោងតាមប្រការ ១៨, ប្រការ ២០ និងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ និងវិធាន ៤.៧ នៃឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ ដែលបានលើកឡើងខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានកាតព្វកិច្ចអញ្ជើញភាគីវិវាទ មកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការសម្រេចសេចក្តី។ ភាគីនៃវិវាទមានកាតព្វកិច្ចត្រូវចូលរួមរាល់កិច្ចប្រជុំទាំងអស់ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញ។ ក្នុងករណីដែលភាគីណាមួយ មិនបានចូលរួមតាមការអញ្ជើញនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចសម្រេចបន្តដំណើរការអាជ្ញាកណ្តាល ដោយអវត្តមានភាគី ឬបញ្ចប់ដំណើរការអាជ្ញាកណ្តាលបាន។ ការសម្រេចជ្រើសរើសជម្រើសណាមួយ នៃជម្រើសទាំងពីរនេះ ត្រូវបំពេញនូវលក្ខខណ្ឌបី គឺលក្ខខណ្ឌទី១ ៖ *ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ,* លក្ខខណ្ឌទី២ ៖ *ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល* និងលក្ខខណ្ឌទី៣ ៖ *ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន*។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានបកស្រាយដែរថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺ *ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ,* លក្ខខណ្ឌទី២ គឺ *ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ* និងលក្ខខណ្ឌទី៣ គឺ *ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន*។ *(សូមមើលសេចក្តីបង្គាប់អាជ្ញា*

*កណ្តាលសំណុំរឿងលេខ ៣០/០៥-មូរៀ, លេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ីម និង វ៉េ ៣, លេខ ៩៥/០៨-យ៉ុង វ៉ា ទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-រីល សិន, លេខ ០៩/០៩-នីមបឹស ថិចថាយ, លេខ ០១/១០-ខិននីតិច, លេខ ៣០/១០-កូប៉ល អាប៉ារែល ,លេខ ១៣០/១៣- ហ្វែន ធើវេន អ៊ីភែរីល ,លេខ ១៦៧/១៣- ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល និងលេខ ២៧០/១៣-៨ ស្តារ ស្ពតវ៉ែរ)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របដែរថា ក្រុមអាជ្ញាកណ្តាលអាចសម្រេចបញ្ចប់ដំណើការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន ដោយផ្អែកលើលក្ខខណ្ឌទាំងបី គឺ លក្ខខណ្ឌទី១ ៖ ភាគីបានទទួលការអញ្ជើញត្រឹមត្រូវ, លក្ខខណ្ឌទី២ ៖ ភាគីខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល និង លក្ខខណ្ឌទី៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

<u>*លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានទទួលការអញ្ជើញត្រឹមត្រូវ*</u>

លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីកម្មករនិយោជិត មកចូលរួមសវនាការអាជ្ញាកណ្តាលយ៉ាងត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញលេខ ១៣៦៧ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ដោយមានភ្ជាប់ជាមួយនូវព័ត៌មានច្បាស់លាស់ អំពីកាលបរិច្ឆេទនៃសវនាការ, ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរស័ព្ទ/ទូរសារ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតបានមកទទួលលិខិតអញ្ជើញ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ វេលាម៉ោង ០៩៖៣០ នាទី ព្រឹក ដោយមានមន្ត្រីសម្របសម្រួលនៃ សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ឈ្មោះ មុំ សុភ័ស្ត ជាអ្នកចុះហត្ថលេខាទទួល ។ លើសពីនេះ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើទំនាក់ទំនងតាមរយៈទូរស័ព្ទ និងបានជូនដំណឹងទៅភាគីកម្មករនិយោជិត ស្តីពីការអញ្ជើញភាគីកម្មករនិយោជិតឱ្យមកចូលរួមសវនាការអាជ្ញាកណ្តាលបន្ថែមទៀត នៅថ្ងៃសវនាការ នាព្រឹកថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតពិតជាទទួលបានការអញ្ជើញ និងជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងនៃសវនាការអាជ្ញាកណ្តាល ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ហេតុនេះ លក្ខខណ្ឌទី ១ ត្រូវបានបំពេញ ។

<u>*លក្ខខណ្ឌទី ២ ៖ ភាគីខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល*</u>

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា *"បង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល"* នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ខាងលើ មានន័យថា ភាគីត្រូវតែ ១) មានវត្តមាននៅក្នុងសវនាការ និង២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាល តាំងពីដើមរហូតដល់ចប់សព្វគ្រប់ ។

ដំណើរការសវនាការអាជ្ញាកណ្តាល ដែលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ និង

ឃ-ដំណាក់កាលសវនាការដល់អង្គសេចក្តី

បន្ថែមលើនេះ ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា ៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬ ដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត មិនបានមានវត្តមាននៅថ្ងៃសវនាការអាជ្ញាកណ្តាលទេ ហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាងត្រឹមត្រូវ ដើម្បីធ្វើជាអ្នកតំណាងពួកគាត់ ក្នុងការមកចូលរួមនៅក្នុងសវនាការអាជ្ញាកណ្តាលនោះដែរ ។ ដូច្នេះ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ ។

***<u>លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន</u>***

តាមរយៈការទំនាក់ទំនងតាមទូរស័ព្ទ ដោយលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទៅកាន់ភាគីកម្មករនិយោជិត នៅកាលបរិច្ឆេទសវនាការ នាព្រឹកថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ អគ្គលេខាធិការរងនៃសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ឈ្មោះ សួស សុខា គ្រាន់តែបានបញ្ជាក់ប្រាប់មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីកម្មករនិយោជិត មិនអាចមកចូលរួមសវនាការអាជ្ញាកណ្តាលបានទេ ដោយមូលហេតុថា កម្មករនិយោជិតឈប់សម្រាកនៅផ្ទះ ដោយសារបញ្ហាកូដកម្ម និងបាតុកម្មទាក់ទងនឹងការដំឡើងប្រាក់ឈ្នួលអប្បបរមា ដែលកើតឡើងរាល់ថ្ងៃ ក្នុងពេលបច្ចុប្បន្ន ហើយក៏មិនមានមន្ត្រីណាម្នាក់នៃសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ អាចមកចូលរួមសវនាការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះបានដែរ ។ លើសពីនេះ លោក សួស សុខា បានស្នើសុំក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យបន្តនីតិវិធីតាមផ្លូវច្បាប់របស់ខ្លួនចុះ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មូលហេតុនេះ មិនមែនជាមូលហេតុត្រឹមត្រូវ សម្រាប់ការមិនបង្ហាញខ្លួនរបស់ភាគីកម្មករនិយោជិតនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា ភាគីកម្មករនិយោជិតមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះទេ ។ ដូច្នេះ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបីដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ ។

បន្ថែមលើនេះ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិត គឺជាភាគីដើមបណ្តឹង ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កាតព្វកិច្ចរបស់ភាគីដើមបណ្តឹង និងភាគីចុងចម្លើយនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗ ដែលពាក់ព័ន្ធនឹងចំណុចវិវាទ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី ។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន ។ ចំណែកឯភាគីចុងចម្លើយវិញ មានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់

ខ្លួនពីការទាមទារ ឬការចោទប្រកាន់ ពីសំណាក់ដើមបណ្តឹង ដែលជាទូទៅកាតព្វកិច្ចនេះ នឹងត្រូវកើតឡើងក្រោយពេលដែលដើមបណ្តឹងបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាមុនសិន។

ក្នុងសំណុំរឿងនេះ ភាគីដើមបណ្តឹងមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដើម្បីការពារបណ្តឹងរបស់ខ្លួនទេ ហើយក៏មិនមានមូលហេតុត្រឹមត្រូវ សម្រាប់ការមិនបង្ហាញខ្លួននេះដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ភាគីដើមបណ្តឹង បានបោះបង់ចោលការទាមទាររបស់ខ្លួនហើយ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនចាំបាច់បន្តដំណើរការអាជ្ញាកណ្តាលនោះទេ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។

ដូច្នេះ យោងតាមការបកស្រាយមកខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាល នៃសំណុំរឿងលេខ ២៧២/១៣-ស្តារឡែថ៍ នេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

- បញ្ចប់ដំណើរការអាជ្ញាកណ្តាល នៃសំណុំរឿងលេខ ២៧២/១៣-ស្តារឡែថ៍។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ ៖ **យូ សួនទី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល**

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា ៖ ------------------------------